# San Diego Unified School District

EUGENE BRUCKER EDUCATION CENTER
4100 Normal Street, San Diego, CA 92103-2682 (619) 725-5506


**Carl A. Cohn**
អគ្គស្នងការក្រសួងអប់រំប្រចាំក្រុង

ខែ វិច្ឆិកា ឆ្នាំ ២០០៧

មាតាបិតា/អ្នកអាណាព្យាបាលសិស្សជាទីរាប់អាន:

ក្រោយពីបានរួចផុតពីគ្រោះភ័យនៃភ្លើងឆាបឆេះនារយៈពេលកន្លងទៅនេះ សិស្ស និងបុគ្គលិកការងាររបស់យើងទាំងអស់បានវិលត្រឡប់មកចូលរៀន និងបំរើការងារវិញ ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីរំលឹកដល់លោក-អ្នកជាមាតាបិតាសិស្សថា ក្រសួងអប់រំប្រចាំទីក្រុង San Diego ផ្តាច់ញ៉ាររក្សាសន្តិសន្តិសុខសិស្សរបស់យើង ក៏ដូចជាការណែនាំសិស្សសិក្សាអោយបានជ័យជំនះផងដែរ។ វាជាការសំខាន់សំរាប់លោកអ្នកឲ្យបានជ្រាបថា សន្តិសុខមានសារៈសំខាន់សំរាប់សិស្សរបស់យើង និងបរិយាកាសនៅតាមសាលារៀនតែមានសំរាប់សិស្សសិក្សាឲ្យបានយ៉ាងល្អប្រសើរផងដែរ។

- ក្រសួងអប់រំប្រចាំទីក្រុង San Diego មានភ្នាក់ងារប៉ូលីសចំនួន ៤៥នាក់ និងភ្នាក់ងារបំរើជួយនៅតាមសហគមន៍ចំនួន ២៦នាក់ដែលចាត់ឲ្យធ្វើការនៅតាមសាលាបឋមសិក្សា, សាលាអនុវិទ្យាល័យ និងសាលាវិទ្យាល័យ។ ភ្នាក់ងារទាំងនេះមានការហ្វឹកហ្វឺនខ្ពស់អាយជួយដោះស្រាយបញ្ហាទូទៅបានទាំងអស់។
- សាលារៀននិមួយៗបានសរសេរ និងរក្សាគម្រោងការសន្តិសុខសិស្សបានយ៉ាងល្អប្រសើរ, មានគម្រោងជួយរំដោះសិស្ស ពេលមានភាពអាសន្នអ្វីមួយ, មានគម្រោងជួយ ពេលមានគ្រោះធម្មជាតិដែលអាចប៉ះពាល់ដល់សិស្ស និងបុគ្គលិកការងារ។ សាលារៀនរបស់យើងធ្វើការហ្វឹកហ្វឺនដល់សិស្ស និងបុគ្គលិកការងារឲ្យចេះរំដោះខ្លួន ពេលមានភាពអាសន្នអ្វីមួយនៅតាមសាលារៀន។
- សាលារៀនរបស់យើងមានក្រុមមាតាបិតា, បុគ្គលិកសាលារៀន និងបុគ្គលិកស្នាក់បំរើជួយដើរយាមល្បាតជួយដល់សិស្សទាំងអស់។ ក្រុមទាំងនេះមានបានទទួលការហ្វឹកហ្វឺនពីក្រុមប៉ូលីសការពារអំពើឧក្រិដ្ឋកម្ម និងជួយផ្តល់ជាភ្នែក ច្រមុះនៅតាមសាលារៀនដើម្បីរក្សាសន្តិសុខសិស្ស។
- យើងមានក្រុមជួយបញ្ឈប់អំពើឧក្រិដ្ឋកម្ម, ដែលជាដៃគូជាមួយក្រុមបញ្ឈប់ឧក្រិដ្ឋកម្មប្រចាំក្រុងស្រុក San Diego ដើម្បីផ្តល់ឱកាសបន្ថែមដល់សិស្ស និងមាតាបិតារាយការស្តីអំពី អំពើឧក្រិដ្ឋកម្មណាមួយបាន។
- ការិយាល័យនៅតាមសាលាវិទ្យាល័យរបស់យើងផ្តល់ការហ្វឹញហ្វឺនដល់គ្រូផ្តល់ឱវាទជួយដល់សិស្សដោះស្រាយបញ្ហាទូទៅបាន។ យើងមានក្រុមសិស្សជួយគាំទ្រធ្វើការដោះស្រាយបង្ហាញអំពី ភាពកំហឹង ព្រមទាំងជួយដល់សិស្សការពារអំពីឧក្រិដ្ឋកម្មបាន។

បច្ចុប្បន្ននេះ សាលារៀនរបស់យើងមានសន្តិសុខ ពីព្រោះមកពីការប្រឹងប្រែងរបស់យើងទាំងអស់គ្នា។ យើងឃើញថា អត្រាផ្នែក ឧក្រិដ្ឋកម្មនៅតាមក្រសួងអប់រំប្រចាំក្រុងរបស់យើងមានការចុះថយ។ ដើម្បីអោយមានការចុះថយបន្ថែម យើងត្រូវការជំនួយពីលោកអ្នកផងដែរ។

ខ្ញុំសូមលើកទឹកចិត្តលោកអ្នកពិគ្រោះជាមួយកូនលោកអ្នកអំពី ច្បាប់បំបាត់មិនអោយសិស្សយកគ្រឿងអាវុធមកសាលារៀន។ លោកអ្នកគួរតែគាំទ្រច្បាប់វិន័យរបស់ក្រសួងអប់រំដែលអាចជួយរៀបចំគម្រោងការសន្តិសុខសិស្សសិក្សា។ ចូរដើរតួរជាសកម្មជូនដល់សាលារៀនរបស់កូន ព្រមទាំងធ្វើកាសិក្សាអំពី គម្រោងសន្តិសុខ និងគម្រោងគ្រោះធម្មជាតិ។ ចូរដើរតួរជាមាតាបិតាគំរូដ៏ល្អមួយរូបដើម្បីដោះស្រាយបញ្ហាឲ្យបានល្អ។

សូមអរគុណដល់លោកអ្នកដែលបានព្យាយាមចូលរួមណែនាំសិស្សឲ្យបានសន្តសុខ និងផ្តល់ឱកាសដល់សិស្សសិក្សា និងព្យាយាមរក្សាបរិយាកាសដល់សាលារៀន។

ដោយក្តីរាក់ទាក់បំផុត

Carl A. Cohn
អគ្គស្នងក្រសួងអប់រំប្រចាំក្រុង

បន្ថែម ចូរចងចាំថា សាលារៀននឹងបិតទ្វារនៅសប្តាហ៍ចាប់ពីថ្ងៃទី ១៩-២៣ ខែ វិច្ឆិកា ពិព្រោះជាសប្តាហ៍ប្រារព្ធបុណ្យថ្លែងអំណរគុណ។ សូមឲ្យលោក-អ្នក និងគ្រួសារទទួលការឈប់បានសុខសាន្ត។